00952534

E300

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 10 / 2013
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**សាធារណៈ / Public**

**អង្គជំនុំជម្រះសាលាដំបូង**

កាលបរិច្ឆេទ៖ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៣

**ជូនចំពោះ:** លោក ម៉ៅ សុភារម្យ ប្រធានមន្ទីរឃុំឃាំង

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** ភាគីទាំងអស់នៃសំណុំរឿង ០០២, លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, ការិយាល័យរដ្ឋបាល

**កម្មវត្ថុ:** សិទ្ធិរបស់ក្រុមមេធាវីការពារក្ដីក្នុងការចូលមន្ទីរឃុំឃាំង

១. នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីទាំងអស់ អំពីកាលវិភាគនៃសវនាការបញ្ចប់ការពិភាក្សាដេញដោល ដែលត្រូវធ្វើចាប់ពីថ្ងៃទី ១៦ រហូតដល់ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៣ (E295/4)។ នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៣ ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានដាក់សំណើតាមរយៈអ៊ីម៉ែលសុំការអនុញ្ញាតចូលមន្ទីរឃុំឃាំង អ.វ.ត.ក ដើម្បីពិគ្រោះយោបល់ជាមួយជនជាប់ចោទ ជារៀងរាល់ថ្ងៃ បន្ទាប់ពីផ្អាកសវនាការបញ្ចប់ការពិភាក្សាដេញដោល និងនៅរាល់ព្រឹកថ្ងៃសៅរ៍ចន្លោះពីថ្ងៃទី ១៦ និងថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៣ ខាងមុខនេះ។ មេធាវីការពារក្ដីបានលើកឡើងថា កាលវិភាគនៃសវនាការបញ្ចប់ការពិភាក្សាដេញដោលនេះ និងថ្ងៃឈប់សំរាករបស់តុលាការកើតឡើងក្នុងអំឡុងពេលជាមួយគ្នាដែលធ្វើឲ្យពួកគាត់មិនអាចពិគ្រោះយោបល់ជាមួយជនជាប់ចោទក្នុងពេលម៉ោងធ្វើការធម្មតាបាន។

00952535



២. ក្នុងកាលៈទេសៈទាំងនេះ អង្គជំនុំជម្រះសាលាដំបូង បានយល់ព្រមអនុញ្ញាតឱ្យមេធាវីការពារក្តីទាំងពីរក្រុម នូវឱកាសបន្ថែមសម្រាប់ចេញចូលមន្ទីរឃុំឃាំង ដែលជាវិធានការលើកលែងក្នុងអំឡុងពេលនៃសវនាការបញ្ចប់ការពិភាក្សាដេញដោលនេះតែប៉ុណ្ណោះ។ បន្ថែមលើពេលម៉ោងធ្វើការធម្មតា អង្គជំនុំជម្រះស្នើឱ្យអង្គភាពទទួលបន្ទុកមន្ទីរឃុំឃាំង អនុញ្ញាតឱ្យក្រុមមេធាវីការពារក្តីបានចូលពិគ្រោះយោបល់ជាមួយកូនក្តីរបស់ពួកគេ ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ រហូតដល់ម៉ោង ៦.៣០ ល្ងាច និងព្រឹកថ្ងៃសៅរ៍ចាប់ពីម៉ោង ៨.០០ ព្រឹក រហូតដល់ ម៉ោង ១២.៣០ ល្ងាច។